F19

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / 03 / 2011
ម៉ោង (Time/Heure): 14:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 001/18-07-2007-ECCC/SC

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រ៊ឹម ប្រធាន**
**ចៅក្រម Motoo NOGUCHI**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Agnieszka KLONOWIECKA MILART**
**ចៅក្រម ស៊ិន រិទ្ធ**
**ចៅក្រម Chandra Nihal Jayasinghe**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** **ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១១**

**ចំណាត់ថ្នាក់ឯកសារ៖** **សាធារណៈ**

---

# ដីកាកំណត់កាលបរិច្ឆេទរៀបចំកិច្ចប្រជុំសវនាការលើបណ្តឹងសាទុក្ខ

---

**សហព្រះរាជអាជ្ញា៖**

ជា លាង
Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១**

ទី ស្រីនណា
Karim KHAN
Alain WERNER
Brianne McGONIGLE

អង្គជំនុំជម្រះតុលាការកំពូល * SUPREME COURT CHAMBER * CHAMBRE DE LA COUR * E.C.C.C * C.E.T.C

**ជនជាប់ចោទ៖**

កាំង ហ្កេកអ៊ាវ ហៅ "ឌុច"

**សហមេធាវីការពារក្តីជនជាប់ចោទ**

ការ សាវុត្ថ

កង ឫទ្ធារី

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម២**

គង់ ពិសី

ហុង គីមសួន

យ៉ុង ផានិត

Silke STUDZINSKY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣**

គីម ម៉េងឃី

ម៉ុច សុវណ្ណារី

Martine JACQUIN
Annie DELAHAIE
Philippe CANONNE
Elizabeth RABESANDRATANA
Fabienne TRUSSES-NAPROUS
Christine MARTINEAU

00649401



**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(“**អ.វ.ត.ក**”):

**កត់សំគាល់ឃើញថា** សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០១ ប្រឆាំងនឹង កាំង ហ្គេក អ៊ាវ *ហៅ* **ឌុច** (“សាលក្រមអង្គជំនុំជម្រះសាលាដំបូង”)ចេញថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១០[1]។

**បានទទួល** បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសាលាដំបូង របស់សហព្រះរាជអាជ្ញា ជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ២ និង៣ (ជារួមហៅថា“*ភាគីបណ្តឹងសាទុក្ខ*”)[2]។

---

[1] E188 (កែតម្រូវ)។

[2] បណ្តឹងសាទុក្ខបន្ទាន់របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ចំពោះការសម្រេចដកឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ចេញពីសាលក្រម, ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០, F8; សារណាបន្ថែមរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ចំពោះ សេចក្តីជូនដំណឹងអំពីគោលបំណង ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០, F12; បណ្តឹងសាទុក្ខរបស់សហមេធាវីតំណាង ដើមបណ្តឹង រដ្ឋប្បវេណីក្រុម៣ ប្រឆាំងទៅនឹងសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១០, F9; បណ្តឹងសាទុក្ខ របស់សហព្រះរាជអាជ្ញាប្រឆាំងទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង កាំង ហ្គេកអ៊ាវ ហៅ ឌុច, ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០, F10 (“សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា”); សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី(ក្រុម២)និងទឡ្ហីករណ៍បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម, ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១០, E188/12; បណ្តឹងសាទុក្ខប្រឆាំងនឹងការបដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសាលក្រម, សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម២, ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០,F11; បណ្តឹងសាទុក្ខ ប្រឆាំងនឹងសាលក្រម ស្តីពីសំណងរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម២, ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១០, F13; សារណាបណ្តឹង សាទុក្ខរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ “ឌុច” ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលា ដំបូងចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០, F14 (“សារណាបណ្តឹង សាទុក្ខ របស់ ជនជាប់ចោទ”); សំណើសុំកែតម្រូវលើសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១០, F14/Corr-1; សំណើសុំ កែតម្រូវលើសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១១, F14/Corr-2; សារណាតបរបស់មេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ទៅនឹងបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តីជនជាប់ចោទប្រឆាំងនឹងសាលក្រម ចុះ ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១០, ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១០, F14/2; និងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង សារណា បណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ “ឌុច” ប្រឆាំងនឹងសាលក្រមសាលាដំបូងចុះ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០, F14/4។ ចម្លើយតប របស់សហព្រះរាជអាជ្ញា ទៅនឹង សារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេក អ៊ាវ ហៅ ឌុច ប្រឆាំងនឹងសាលក្រមអង្គជំនុំ ជម្រះសាលាដំបូងចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០, F14/4; ការឆ្លើយ តបរបស់សហមេធាវីការពាក្តី ជនជាប់ចោទ ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០, ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១, F14/4/2។

**រំលឹកឡើងវិញថា** ដោយអនុលោមតាមវិធាន១០៨(៣)នៃវិធានផ្ទៃក្នុង(វិសោធនកម្មលើកទី ៦) ក្រឡាបញ្ជីនៃអង្គជំនុំជម្រះ បានជូនដំណឹងដល់ភាគីទាំងអស់នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ ថាអង្គជំនុំជម្រះតុលាការកំពូល នឹងបើកសវនាការលើបណ្តឹងសាទុក្ខចាប់ពីថ្ងៃច័ន្ទ ទី២៨ ដល់ ថ្ងៃព្រហស្បតិ៍ ទី៣១ ខែមីនា ឆ្នាំ២០១១ ហើយថា "កាលបរិច្ឆេទសវនាការ ដូចជាការកំណត់កាលបរិច្ឆេទ និងពេលវេលាច្បាស់លាស់ នឹងត្រូវជូនដំណឹងតាមពេលវេលាសមស្រប" ។

**រំលឹកឡើងវិញថា** នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល បានស្នើសុំភាគីបណ្តឹងសាទុក្ខឱ្យធ្វើការបញ្ជាក់នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ ថាអ្នកតំណាងផ្នែកច្បាប់របស់ខ្លួន នឹងអាចចូលរួមក្នុងកិច្ចប្រជុំរៀបចំសវនាការបណ្តឹងសាទុក្ខនេះជាមួយនឹងអង្គជំនុំជម្រះ នៅថ្ងៃពុធ ឬ ព្រហស្បតិ៍ ថ្ងៃទី២៣ ឬ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ នៅភ្នំពេញ ហើយថាក្រឡាបញ្ជីបានទទួលការអះអាងបញ្ជាក់នេះពីភាគីបណ្តឹងសាទុក្ខទាំងអស់ នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១។

**រំលឹកឡើងវិញថា** នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១ ក្រឡាបញ្ជី នៃអង្គជំនុំជម្រះ បានជូនដំណឹងដល់ភាគីបណ្តឹងសាទុក្ខ ថាអង្គជំនុំជម្រះ បើកកិច្ចប្រជុំរៀបចំសវនាការបណ្តឹងសាទុក្ខ នៅថ្ងៃពុធ ទី២៣ ខែមីនា ឆ្នាំ២០១១។

## ហេតុដូច្នេះ

**បង្គាប់ថា** កិច្ចប្រជុំរៀបចំសវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០១/១៨/កក្កដា/២០០៧ នឹងចាប់ផ្តើមនៅថ្ងៃពុធ ទី២៣ ខែមីនា ឆ្នាំ២០១១ វេលាម៉ោង៩:០០ ព្រឹក(ពេលវេលាក្នុងស្រុក)ក្នុងបន្ទប់សវនាការនៃអ.វ.ត.ក និងបញ្ចប់នៅម៉ោង១៦:០០ ល្ងាច។

**បង្គាប់ថា** កិច្ចប្រជុំរៀបចំសវនាការបណ្តឹងសាទុក្ខ នឹងធ្វើឡើងជាអសាធារណៈ។



SUPREME COURT CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE LA COUR SUPRÊME

00649403

០០១/១៨ កក្កដា ២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ឯកសារលេខ. F19

**បង្គាប់ថា** ជនជាប់ចោទ កាំង ហ្គេចអ៊ាវ ហៅ ឌុច  និងភាគីបណ្តឹងសាទុក្ខដើមបណ្តឹងរដ្ឋប្បវេណីជាបុគ្គល មិនអាចចូលរួមក្នុងកិច្ចប្រជុំរៀបចំសវនាការលើបណ្តឹងសាទុក្ខបាននេះឡើយ។

**ភ្ជាប់ជាមួយ** នូវរបៀបវារៈក្នុងឧបសម្ព័ន្ធ១ស្តីពីកិច្ចប្រជុំរៀបចំសវនាការបណ្តឹងសាទុក្ខ។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១១

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ីម**